# ប្រវត្តិរូប
# បណ្ឌិតសភាចារ្យ អ៊ីវ ច័ន



រៀបរៀង

វិទ្យាស្ថានភាសាជាតិ នៃរាជបណ្ឌិត្យសភាកម្ពុជា

ភ្នំពេញ

ព.ស.២៥៥៨ គ.ស.២០១៤

([illegible])

# អារម្ភកថា

ជីវប្រវត្តិរបស់ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត **អ៊ុំ ច័ន** ដែលចងក្រងឡើងដោយវិទ្យាស្ថានភាសាជាតិនៃរាជ្យបណ្ឌិតសភាកម្ពុជានេះជាការរំឭកដល់គុណូបការៈនិងការរួមចំណែករបស់បណ្ឌិតសភាចារ្យ **អ៊ុំ ច័ន** ដែលបានបូជា កម្លាំងកាយ កម្លាំងប្រាជ្ញាស្មារតី ក្នុងវិស័យ អក្សរសាស្ត្រ ប្រវត្តិសាស្ត្រ និង វប្បធម៌។

ឯកឧត្តមបណ្ឌិតសភាចារ្យ **អ៊ុំ ច័ន** ជាបញ្ញវន្តខ្មែរមួយរូបដែលមានគុណធម៌គួរឱ្យគោរព។ ក្រៅពីរាជបណ្ឌិត្យសភាកម្ពុជា នៅតាមសាកលវិទ្យាល័យរដ្ឋនិងឯកជន ឯកឧត្តមបានរួមវិភាគទានយ៉ាងច្រើនក្នុងជួយបណ្ដុះបណ្ដាលនិស្សិតនិងអ្នកស្រាវជ្រាវជាតិនិងអន្តរជាតិជំនាន់ក្រោយ។ លោកបានចូលយ៉ាងជ្រៅក្នុងវិស័យអក្សរសាស្ត្រនិងប្រវត្តិសាស្ត្រ តាំងពីពេលលោកអញ្ជើញទៅសិក្សាស្រាវជ្រាវនៅអតីតសហភាពសូវៀតមកម្ល៉េះ។

នាបច្ឆិមវ័យនៃជីវិត ឯកឧត្តមបណ្ឌិតសភាចារ្យ **អ៊ុំ ច័ន** បានចូលរួមចំណែកយ៉ាងគួរឱ្យកត់សម្គាល់ក្នុងឋានៈឯកឧត្តមជាអនុប្រធានក្រុមប្រឹក្សាជាតិភាសាជាតិខ្មែរ (ក.ជ.ភ.ខ.) ក្នុងបេសកកម្ម និង ភារកិច្ចស្វែងរកឯកភាពឱ្យភាសាខ្មែរ ទាំងក្នុងសំណេរ ទាំងក្នុងការប្រើប្រាស់ ព្រមទាំងឯកភាពក្នុងកម្ចីពាក្យពីភាសាបរទេស។ ដោយឡែក ក្នុងវិស័យវចនលេខន៍ (lexicography) លោកបានដឹកនាំបុគ្គលិកវិទ្យាស្ថានភាសាជាតិលើការដាក់សូរមេពាក្យនៃ **វចនានុក្រមអក្ខរាវិរុទ្ធនៃភាសាខ្មែរ** បោះពុម្ពផ្សាយគ.ស.២០០៥ ដែលជាស្នាដៃកើតចេញពីការដឹកនាំរបស់បណ្ឌិតសភាចារ្យ **ឡុង សៀម**។ ជាបន្ថែម ក្រៅពីការដាក់ពាក្យវចនានុក្រមនេះក៏មានបន្ថែមពាក្យជាច្រើនថែមទៀតផងដែរ។

វិទ្យាស្ថានភាសាជាតិ ក៏ដូចជនរួមជាតិខ្មែរទាំងមូល ចងចាំជានិច្ចនូវគុណូបការៈនិងការរួមចំណែកដ៏ឧត្តុង្គឧត្តមរបស់ឯកឧត្តមចំពោះប្រទេសជាតិ និងសូមលំឱនកាយឧទ្ទិសសៀវភៅនេះជូនដួងវិញ្ញាណក្ខន្ធរបស់ឯកឧត្តម សូមឯកឧត្តមទទួលបានទិព្វសម្បត្តិក្នុងសុខគតិភពលុះកប្បាវសាន។

រាជធានីភ្នំពេញ, ថ្ងៃចន្ទ ទី១៥ ធ្នូ គ.ស.២០១៤

**វិទ្យាស្ថានភាសាជាតិ**

# មាតិកា

ទំព័រ

១. ស្រុកកំណើត និង ក្រុមគ្រួសារ ........................................ ១

២. ការសិក្សា ........................................................... ១

៣. ការងារ និង បេសកកម្ម ............................................ ២

៤. កិច្ចការស្រាវជ្រាវនិងស្នាដៃ ........................................ ៤

៥. អំពីឥស្សរិយយស ................................................. ៥

៦. ជីវិតអាពាហ៍ពិពាហ៍ ............................................... ៦

៧. ស្ថានភាពមុនពេលទទួលមរណភាព ................................ ៦

៨. ស្ថានភាពក្រោយទទួលមរណភាព ................................ ៦

៩. ទំព័ររូបថត ........................................................ ៨

# ប្រវត្តិរូប

*ឯកឧត្តមបណ្ឌិតសភាចារ្យ* **អ៊ុំ ច័ន**
*សមាជិកពេញសិទ្ធិនៃរាជបណ្ឌិត្យសភាកម្ពុជា*
*ប្រធានវិទ្យាស្ថានភាសាជាតិនៃរាជបណ្ឌិត្យសភាកម្ពុជា*
*អនុប្រធានក្រុមប្រឹក្សាជាតិភាសាខ្មែរ*

## ១. ស្រុកកំណើត និង ក្រុមគ្រួសារ

ឯកឧត្តមបណ្ឌិតសភាចារ្យ **អ៊ុំ ច័ន** ប្រសូតនៅថ្ងៃទី០៩ ខែធ្នូ ឆ្នាំ១៩៤២ ក្នុងភូមិព្រៃល្វា ឃុំព្រៃល្វា ស្រុកព្រៃកប្បាស ខេត្តតាកែវ ក្នុងត្រកូលកសិករដែលមានឪពុកឈ្មោះ **អ៊ុំ ណា** និងម្ដាយឈ្មោះ **អៀង ណាយ** និងមានបងប្អូនប្រុសស្រីចំនួន០៥នាក់, លោកជាកូនទី២នៅក្នុងគ្រួសារ។

## ២. ការសិក្សា

កាលពីវ័យកុមារ ឯកឧត្តមបណ្ឌិតសភាចារ្យ **អ៊ុំ ច័ន** បានចូលសិក្សានៅសាលាបឋមសិក្សាព្រៃល្វា ក្នុងឃុំព្រៃល្វា ស្រុកព្រៃកប្បាស ខេត្តតាកែវ រហូតដល់បញ្ចប់ថ្នាក់នៅទីនោះ។

ដោយសារទទួលបានជោគជ័យក្នុងការសិក្សា ឯកឧត្តមបណ្ឌិតសភាចារ្យ **អ៊ុំ ច័ន**ទទួលបាននូវសញ្ញាបត្រជាបន្តបន្ទាប់ដូចតទៅ៖

- ឆ្នាំ១៩៦៦-១៩៦៧ : សញ្ញាបត្រគរុកោសល្យឯកទេសធម្មជាតិគីមីវិទ្យា។
- ឆ្នាំ១៩៦៧-១៩៧២ : សញ្ញាបត្របរិញ្ញាបត្រឯកទេសអក្សរសាស្ត្រខ្មែរនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។

- ឆ្នាំ១៩៨៥-១៩៨៧ : សញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ឯកទេសចិត្ត-វិទ្យានៃសាកលវិទ្យាល័យមូស្គូ។
- ឆ្នាំសិក្សា១៩៨៧-១៩៩២ : សញ្ញាបត្របណ្ឌិតឯកទេសប្រវត្តិ-សាស្ត្រខ្មែរនៅវិទ្យាស្ថានបូព៌ានៃបណ្ឌិត្យសភាវិទ្យាសាស្ត្រនៅសហព័ន្ធរុស្ស៊ី ចំណងជើងនិក្ខេបបទ «ប្រវត្តិសង្គមសេដ្ឋកិច្ចនយោបាយរបស់ប្រទេសកម្ពុជានៅស.វ.ទី១៤-១៥»។

## ៣. ការងារ និង បេសកកម្ម

ទន្ទឹមនឹងជោគជ័យដ៏ត្រចះត្រចង់ក្នុងការសិក្សាខាងលើនេះ ឯកឧត្តមបណ្ឌិតសភាចារ្យ **អ៊ឹម ច័ន** ក៏មានជោគជ័យប្រកបដោយមោទនភាពនៅក្នុងវិជ្ជាជីវៈជាសាស្ត្រាចារ្យ ក្នុងឋានៈជាអ្នកដឹកនាំស្ថាប័នជាតិជាន់ខ្ពស់ និង ចូលរួមជាសមាជិកគណៈកម្មការជាតិនិងអន្តរជាតិជាច្រើនជាបន្តបន្ទាប់ ដូចតទៅ៖

- ពីឆ្នាំ១៩៦៧ ដល់ឆ្នាំ១៩៦៩ : សាស្ត្រាចារ្យមុខវិជ្ជាជីវវិទ្យា គីមីវិទ្យា រូបវិទ្យា និង ភាសាខ្មែរនៅអនុវិទ្យាល័យក្រាំងស្លា។
- ពីឆ្នាំ១៩៦៩ ដល់ ឆ្នាំ១៩៧៣ : សាស្ត្រាចារ្យមុខវិជ្ជារូបវិទ្យានិងភាសាខ្មែរនៅអនុវិទ្យាល័យបែកចាន។
- ពីឆ្នាំ១៩៧៣ ដល់ ឆ្នាំ១៩៧៥ : សាស្ត្រាចារ្យមុខវិជ្ជារូបវិទ្យា និងភាសាខ្មែរនៅវិទ្យាល័យដម្លូវ៉ែ។
- ពីឆ្នាំ១៩៧៩ ដល់ ឆ្នាំ១៩៨០ : សាស្ត្រាចារ្យមុខវិជ្ជាភាសាខ្មែរនៅវិទ្យាល័យកម្ពុជបុត្រ។

- ពីឆ្នាំ១៩៨០ ដល់ ឆ្នាំ១៩៨៥ : សាស្ត្រាចារ្យមុខវិជ្ជាភាសាខ្មែរ និង សីលធម៌នយោបាយនៅវិទ្យាល័យភ្នំដូនពេញ (ព្រះស៊ីសុវត្ថិ)។
-ពីឆ្នាំ១៩៩២ ដល់ ឆ្នាំ១៩៩៩ : សាស្ត្រាចារ្យមុខវិជ្ជាប្រវត្តិសាស្ត្រខ្មែរ នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។
- ពីឆ្នាំ១៩៨២ ដល់ ឆ្នាំ១៩៨៥ : នាយករងនៅវិទ្យាល័យភ្នំដូនពេញ (វិទ្យាល័យស៊ីសុវត្ថិ)
- ពីឆ្នាំ១៩៩៥ ដល់ ឆ្នាំ១៩៩៦ : អគ្គលេខាធិការកំណែទម្រង់ឧត្តមសិក្សា។
- ពីឆ្នាំ១៩៩៥ ដល់ ឆ្នាំ១៩៩៧ : អនុប្រធានដេប៉ាតេម៉ង់ប្រវត្តិវិទ្យានៃសាកលវិទ្យាល័យភ្នំពេញ។
- ពីឆ្នាំ១៩៩៧ ដល់ ឆ្នាំ១៩៩៨ : ប្រធានដេប៉ាតេម៉ង់ប្រវត្តិវិទ្យានៃសាកលវិទ្យាល័យភ្នំពេញ។
- ពីឆ្នាំ១៩៩៩ ដល់ ឆ្នាំ២០០៧ : អនុប្រធានវិទ្យាស្ថានភាសាជាតិនៃរាជបណ្ឌិត្យសភាកម្ពុជា។
- ពីឆ្នាំ២០០២ ដល់ ឆ្នាំ២០១៣ : សមាជិកពេញសិទ្ធិនៃរាជបណ្ឌិត្យសភាកម្ពុជា។
- ពីឆ្នាំ២០០៣ ដល់ ឆ្នាំ២០០៨ : អគ្គលេខាធិការគណៈកម្មាធិការវប្បធម៌កម្ពុជា-ថៃ។
- ពីឆ្នាំ២០០៣ ដល់ ឆ្នាំ២០១៣ : សមាជិកគណៈកម្មការបណ្ឌិត្យសភាទទួលបន្ទុកអនុម័តពាក្យច្បាប់។
- ពីឆ្នាំ២០០៧ ដល់ ឆ្នាំ២០១៣ : ប្រធានវិទ្យាស្ថានភាសាជាតិនៃរាជ-បណ្ឌិត្យសភាកម្ពុជា។

- ពីឆ្នាំ២០១១ ដល់ ឆ្នាំ២០១៣ : អនុប្រធានក្រុមប្រឹក្សាជាតិភាសាខ្មែរ។
- ខែកក្កដាឆ្នាំ២០១៣ : ទីប្រឹក្សាសមាគមអ្នកប្រវត្តិសាស្ត្រកម្ពុជា។
- ពីឆ្នាំ១៩៩៥ ដល់ ឆ្នាំ១៩៩៩ : សាស្ត្រាចារ្យបង្រៀនប្រវត្តិសាស្ត្រ និងដឹកនាំស្រាវជ្រាវធ្វើសារណានិងនិក្ខេបបទ នៅមហាវិទ្យាល័យអក្សរសាស្ត្រនិងមនុស្សសាស្ត្រនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។
- ពីឆ្នាំ១៩៩៩ ដល់ ឆ្នាំ២០១៣ : សាស្ត្រាចារ្យបង្រៀនប្រវត្តិសាស្ត្រ និងដឹកនាំស្រាវជ្រាវធ្វើនិក្ខេបបទនៅរាជបណ្ឌិត្យសភាកម្ពុជា។

ឯកឧត្តមបណ្ឌិតសភាចារ្យ **អ៊ឹម ច័ន** ជាសមាជិកគណៈកម្មាធិការ គណៈកម្មការជាតិ ជាច្រើនទៀត នៅក្នុងដំណាក់កាលកសាងនិងអភិវឌ្ឍប្រទេសជាតិកន្លងមក។ ឯកឧត្តមធ្លាប់ធ្វើទស្សនកិច្ចសិក្សានៅប្រទេសមួយចំនួន ដូចជា ប្រទេសឡាវ, ប្រទេសវៀតណាម, ប្រទេសថៃ, ប្រទេសជប៉ុន, ប្រទេសហុងគ្រី, ប្រទេសឆេកូស្លូវ៉ាគី និង ប្រទេសហ្វីលីពីន ជាដើម។

## ៤. កិច្ចការស្រាវជ្រាវនិងស្នាដៃ

- ឆ្នាំ១៩៨៧ : អ្នកត្រួតពិនិត្យវចនានុក្រមរុស្ស៊ី-ខ្មែរ។
- ស្នាដៃស្រាវជ្រាវអំពីប្រវត្តិសាស្ត្រខ្មែរ : ភូមិភាគបូព៌ានៃកម្ពុជាប្រជាធិបតេយ្យពីឆ្នាំ១៩៧៥-១៩៧៩នៅទីក្រុងភ្នំពេញ។
- ឆ្នាំ១៩៩៥- ១៩៩៧ : អគ្គលេខាធិការក្រុមការងារជាតិសម្រាប់ឧត្តមសិក្សា។
- ឆ្នាំ១៩៩៦ : អត្ថបទស្រាវជ្រាវអំពីប្រវត្តិសាស្ត្រខ្មែរ International

Conference on Cambodia : Power, Myth and Memory, Monash University, Australia.

- ឆ្នាំ១៩៩៨ : ត្រួតពិនិត្យសទ្ទានុក្រមបច្ចេកសព្ទឧត្តមសិក្សា។
- ឆ្នាំ១៩៩៨ : ប្រវត្តិសាស្ត្រសម័យមហានគរសម្រាប់មគ្គុទ្ទេសក៍ទេសចរណ៍ (ក្រសួងទេសចរណ៍)។
- ឆ្នាំ១៩៩៩ : ទស្សនាវដ្ដី"សំណើបង្កើតគណៈកម្មាធិការជាតិសម្រាប់អភិវឌ្ឍន៍ឧត្តមសិក្សានៅកម្ពុជា"។
- ឆ្នាំ២០០៥ : នាទីបទសម្ភាសន៍អក្សរសាស្ត្រខ្មែររបស់សម្តេចព្រះសង្ឃរាជ ជួន ណាត (វិទ្យាស្ថានភាសាជាតិ )។
- ឆ្នាំ២០០៦ : និពន្ធនាយករងវចនានុក្រមអក្ខរាវិរុទ្ធនៃភាសាខ្មែរ។
- ឆ្នាំ២០០៦ : ភាសាមន-ខ្មែរ«ទស្សនាវដ្ដីវិទ្យាស្ថានភាសាជាតិលេខ៥»
- ឆ្នាំ២០០៧ : ប្រវត្តិសាស្ត្រពេទ្យ (បោះពុម្ពដោយសាកលវិទ្យាល័យអន្តរជាតិភ្នំពេញ)។
- ឆ្នាំ២០១៣ : ត្រៀមបោះពុម្ព(លើកទី២) និពន្ធនាយកវចនានុក្រមអក្ខរាវិរុទ្ធនៃភាសាខ្មែរ។

## ៥- **អំពីឥស្សរិយយស** :

- គ្រឿងឥស្សរិយយសព្រះរាជាណាចក្រកម្ពុជា ថ្នាក់មហាសេនា : ព្រះរាជក្រឹត្យលេខពរល១១០៣.៣២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១១
- មេដាយមុនីសារាភ័ណ្ឌថ្នាក់ធិបឌិន្ទ : អនុក្រឹត្យលេខ ២៣០អនក្រ.តក ចុះថ្ងៃទី០៧ខែមេសាឆ្នាំ២០០៦។
- មេដាយមាសការងារ : អនុក្រឹត្យលេខ ២៨១ អនក្រ.តក ចុះថ្ងៃទី ០៤ ខែឧសភា ឆ្នាំ២០០៦។

## ៦. ជីវិតអាពាហ៍ពិពាហ៍

ឯកឧត្តមបណ្ឌិតសភាចារ្យ **អ៊ីវ ច័ន** បានរៀបអាពាហ៍ពិពាហ៍ជាមួយកញ្ញា **លាង រ៉ានី** មន្ត្រីអគ្គនាយកដ្ឋានវិទ្យុជាតិ នៃក្រសួងព័ត៌មាន និងទទួលបានកូនប្រុសពីរនាក់ ៖

- ឆ្នាំ១៩៨២ : មានកូនប្រុសម្នាក់ឈ្មោះ អ៊ីវ ច័ន្ទណារ៉ា
- ឆ្នាំ១៩៨៩ : មានកូនប្រុសម្នាក់ទៀតឈ្មោះ អ៊ីវ ច័ន្ទរតនៈ

## ៧. ស្ថានភាពមុនពេលទទួលមរណភាព

ឯកឧត្តមបណ្ឌិតសភាចារ្យ **អ៊ីវ ច័ន** បានទទួលមរណភាពកាលពីថ្ងៃសៅរ៍ ទី២៦ ខែតុលា ឆ្នាំ២០១៣ វេលាម៉ោង១១និង១៥នាទីព្រឹក ក្នុងជន្មាយុ៧១ឆ្នាំ ដោយរោគាពាធនៅក្នុងមន្ទីរពេទ្យកាល់ម៉ែត្រ បន្ទាប់ពីបានព្យាបាលអស់ពេលជាច្រើនឆ្នាំនៅមន្ទីរពេទ្យក្នុងនិងក្រៅប្រទេស។

## ៨. ស្ថានភាពក្រោយទទួលមរណភាព

ក្រោយពេលឯកឧត្តមបណ្ឌិតសភាចារ្យ **អ៊ីវ ច័ន** បានទទួលមរណភាព ដំណឹងបានផ្សព្វផ្សាយទៅគ្រប់មជ្ឈដ្ឋាន មាន ថ្នាក់ដឹកនាំ មន្ត្រីរាជការ និស្សិត ព្រមទាំង ញាតិមិត្ត ហើយ អ្នកដែលបានចូលរួមមាន ព្រះសំវរវិជ្ជា **សុខ ប៊ុនធឿន** ចៅអធិការវត្តនន្ទមុនី, ឯកឧត្តមបណ្ឌិតសភាចារ្យ **ទ្រាំ ម៉ល់** ប្រធានក្រុមប្រឹក្សាជាតិភាសាខ្មែរ, ឯកឧត្តមបណ្ឌិតសភាចារ្យ **ស៊ុំ ឈុំប៊ុន**, ឯកឧត្តមបណ្ឌិតសភាចារ្យ **ឆយ អូន**, ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត **នេត បារ៉ុម**, ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត **នៅ ស៊ីន**, ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត **ម៉ៅ សុក្កុន**, ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត **ប៉ែន ប៊ុនពីរ**, ឯកឧត្តម **ហង់**

**ជួនណារ៉ុន** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា, ឯកឧត្តម **សូ មុយឃៀង**, ឯកឧត្តម **លី សុមុនី**, ឯកឧត្តម **ហ៊ឹង ថូរ៉ាក់ស៊ី**, លោកស្រីបណ្ឌិត **ព្រុំ ធេវី**, ឯកឧត្តម **អ៊ុំ ម៉ុម**, ឯកឧត្តម **ម៉ៅ ថូរ៉ា**, ឯកឧត្តម **អ៊ុច ថុន**, ... ព្រម ទាំងឥស្សរជន និង មន្ត្រីដទៃទៀតដែលអញ្ជើញមកពីស្ថាប័នរដ្ឋនិងឯកជន ដូចជារាជបណ្ឌិត្យសភាកម្ពុជា, សមាគមសង្គហៈទីស្តីការគណៈរដ្ឋមន្ត្រី, ក្រុមប្រឹក្សាជាតិភាសាខ្មែរ, សកលវិទ្យាល័យភូមិន្ទភ្នំពេញ, សកលវិទ្យាល័យ បាត់ដំបង, សកលវិទ្យាល័យអន្តរជាតិ, សមាគមអ្នកប្រវត្តិសាស្ត្រ, ក្រសួង ព័ត៌មាន, អគ្គនាយកដ្ឋានវិទ្យុជាតិ, វិទ្យាល័យព្រះស៊ីសុវត្ថិ, អង្គការ ICC, ...។

# ៩. ទំព័ររូបថត



ឯកឧត្តមបណ្ឌិតសភាចារ្យ អ៊ីវ ច័ន នៅវ័យក្មេង



អំឡុងពេលរៀននៅរុស្ស៊ី (១៩៨៥-១៩៩២)



(ពីស្តាំ ទៅឆ្វេងដៃ) **បណ្ឌិតសភាចារ្យ អ៊ីវ ច័ន ចូលក្រាបបង្គំគាល់អតីតព្រះមហាវីរក្សត្រសម្តេចព្រះ នរោត្តម សីហនុ ព្រះបរមរតនកោដ្ឋ និង ព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ**



( ពីឆ្វេងទៅស្តាំដៃ ) **បណ្ឌិតសភាចារ្យ អ៊ីវ ច័ន, បណ្ឌិតសភាចារ្យ ខ្លូត ធីតា និង**

**បណ្ឌិតសភាចារ្យ ឡុង សៀម**



ចូលរួមសិក្ខាសាលា

(ពីឆ្វេងទៅស្តាំដៃ) បណ្ឌិតសភាចារ្យ សោម សុមុនី, បណ្ឌិត កង ឌិម, បណ្ឌិតសភាចារ្យ អ៊ីវ ច័ន, បណ្ឌិតសភាចារ្យ ត្រំ ម៉ល់, បណ្ឌិត ហ្សាក់ រ៉ុងហ្សេ

(Jacque RONGIER)




**បណ្ឌិតសភាចារ្យ អ៊ីវ ច័ន ចូលរួមសិក្ខាសាលាអន្តរជាតិ**

(រូបទី៤ ពីឆ្វេងទៅស្តាំដៃ)




បណ្ឌិតសភាចារ្យ អ៊ីវ ច័ន ចូលរួមសិក្ខាសាលានៅប្រទេសថៃ ឆ្នាំ២០០៨

(រូបទី៤ ពីស្តាំទៅឆ្វេងដៃ)

ឯកឧត្តមបណ្ឌិត អ៊ីវ ច័ន ទីប្រឹក្សាសមាគមអ្នកប្រវត្តិសាស្ត្រកម្ពុជា




ឯកឧត្តមបណ្ឌិត អ៊ីវ ច័ន រូបទី៤ ជួរមុខ ពីឆ្វេងទៅស្តាំ

# រូបថតអនុស្សាវរីយ៍
# បង្ហាញអំពីសកម្មភាពរបស់
# ឯកឧត្តមបណ្ឌិត អ៊ីវ ច័ន

រៀបចំដោយ សមាគមអ្នកប្រវត្តិសាស្ត្រកម្ពុជា
ថ្ងៃទី២៨ តុលា ២០១៣



លោកសាស្ត្រាចារ្យបណ្ឌិត អ៊ីវ ច័ន (រូបទី១ ជួរខាងមុខ ពីឆ្វេងទៅស្តាំ)
ក្នុងដំណើរការបង្កើត បណ្ឌិតសភាប្រវត្តិសាស្ត្រ នៅខែមករា ១៩៩៨
នៅអគារទី១ នៃរាជបណ្ឌិតសភាកម្ពុជា

លោកសាស្ត្រាចារ្យបណ្ឌិត អ៊ី ច័ន (បទី៣ ពីឆ្វេងទៅស្តាំ)

International Conference on Cambodia: Power, Myth and Memory

Monash University, Melbourn, Australia, 1996



ឯកឧត្តមបណ្ឌិត អ៊ី ច័ន (បទី៨ ជួរមុខ ពីឆ្វេងទៅស្តាំ

At the Royal Academy of Cambodia in 2001

អនុប្រធានដេប៉ាតឺម៉ង់ប្រវត្តិវិទ្យានៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ
ក្នុងដំណើរការបង្កើត បណ្ឌិតសភាប្រវត្តិសាស្ត្រ នៅខែមករា ១៩៩៨



លោកសាស្ត្រាចារ្យបណ្ឌិត អ៊ីវ ច័ន (រូបទី៣ ពីឆ្វេងទៅស្តាំ)
International Conference on Cambodia: Power, Myth and Memory
Monash University, Melbourn, Australia, 1996



លោកសាស្ត្រាចារ្យបណ្ឌិត អ៊ីវ ច័ន (រូបទី៥ ពីឆ្វេងទៅស្តាំ)

Indian Ambassador's visit to Royal Academy of Cambodia in October 2002

# រូបថតពេលពិធីបុណ្យសព

( ពីថ្ងៃសៅរ៍-ចន្ទ ទី២៦-២៨ ខែតុលា ឆ្នាំ២០១៣ )













បណ្ឌិតសភាចារ្យ អ៊ីវ ច័ន្ទ និង ក្រុមគ្រួសារ